## ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខ: ០៥៦/១៦ ក.អ.ជ. សរ

ថ្ងៃអង្គារ ២ កើត ខែ មាឃ ឆ្នាំ មមែ ព.ស. ២៥៥៩
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ គ.ស. ២០១៦

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទសម្រាប់តាមដានព័ត៌មាន Facebook របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្ម លើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ ១._** បង្កើតក្រុមការងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទសម្រាប់តាមដានព័ត៌មាន Facebook របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ដែលមានការពាក់ព័ន្ធនឹងក្រសួងអភិវឌ្ឍន៍ជនបទ ដូចមានសមាសភាពខាងក្រោម ÷ ។

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **សួស គង់** | រដ្ឋលេខាធិការ | ប្រធាន |
| ២. | លោក **ទូច ស៊ីផាត** | ប្រធានការិ. ស្រាវជ្រាវ | អនុប្រធាន |
| ៣. | កញ្ញា **នូសុទត្ថិ ចាន់ចត្តី** | មន្ត្រីខុទ្ទកាល័យ | សមាជិកា |
| ៤. | កញ្ញា **ហែម សុហ៊ីយ៉ា** | អនុប្រធានការិ. សម្ភារៈ | សមាជិកា |
| ៥. | កញ្ញា **ចំនួ សុរិយា** | អនុប្រធានការិ. កិច្ចការទូទៅ | សមាជិកា |

**ប្រការ ២._** ក្រុមការងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទសម្រាប់តាមដានព័ត៌មាន Facebook របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មានតួនាទី និងភារកិច្ចតាមដានមតិមហាជន ដែលបង្ហោះនៅក្នុងទំព័រ Facebook របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងវិស័យអភិវឌ្ឍន៍ជនបទ ។

**ប្រការ ៣._** ក្រុមការងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទសម្រាប់តាមដានព័ត៌មាន Facebook របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤._** សេចក្តីសម្រេចណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥._** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាន ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត គ្រប់អង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ និងសាមីខ្លួន មានភារកិច្ចអនុវត្តតាមសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ជា សុផារ៉ា**

<u>**កន្លែងទទួល ÷**</u>

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាតេជោ នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
  (ដើម្បីជូនជ្រាប)
- ដូចមានចែងក្នុងប្រការ ១ និង ៥
  (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ